# ធជគ្គសូត្រ (ធមិធជគ្គបរិត្ត)

## (បិដក អដ្ឋកថា ដីកា)

## (បិដកភាគ ៣០ ទំព័រ២៤៣)



រៀបរៀងប្រែដោយភិក្ខុ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# សេចក្តីផ្តើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះនឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្តីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្តីសុខ សេចក្តីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្តីសុខ សេចក្តីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

*វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី០៧ ខែមេសាឆ្នាំ២០២៣*

ភិក្ខុសារត្ថធម្មោ នួន សារ៉េត

## ៣ .ធជគ្គសុត្តំ (បិដក)

[៣៤២] សាវត្ថិយំ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ “ភិក្ខវោ”តិ ។ “ភទន្តេ”តិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ។ ភគវា ឯតទវោច

“ភូតបុព្វំ, ភិក្ខវេ, ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ។ អថ ខោ, ភិក្ខវេ, សក្កោ ទេវានមិន្ទោ ទេវេ តាវតិំសេ អាមន្តេសិ

‘សចេ, មារិសា, ទេវានំ សង្គាមគតានំ ឧប្បជ្ជេយ្យ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, មមេវ តស្មិំ សមយេ ធជគ្គំ ឧល្លោកេយ្យាថ។ មមញ្ហិ វោ ធជគ្គំ ឧល្លោកយតំ យំ ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, សោ បហីយិស្សតិ’ ។

‘នោ ចេ មេ ធជគ្គំ ឧល្លោកេយ្យាថ, អថ បជាបតិស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ។ បជាបតិស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ យំ ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, សោ បហីយិស្សតិ’ ។

‘នោ ចេ បជាបតិស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ, អថ វរុណស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ។ វរុណស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ យំ ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, សោ បហីយិស្សតិ’ ។

‘នោ ចេ វរុណស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ, អថ ឦសានស្ស ទេវរាជស្ស ធជគ្គំ ឧល្លោកេយ្យាថ។ ឦសានស្ស ហិ វោ ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ យំ ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, សោ បហីយិស្សតី’”តិ។

“តំ ខោ បន, ភិក្ខវេ, សក្កស្ស វា ទេវានមិន្ទស្ស ធជគ្គំ ឧល្លោកយតំ, បជាបតិស្ស វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ, វរុណស្ស វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ, ឦសានស្ស

វា ទេវរាជស្ស ធជគ្គំ ឧល្លោកយតំ យំ ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, សោ
បហីយេថាបិ នោបិ បហីយេថ។

“តំ កិស្ស ហេតុ? សក្កោ ហិ, ភិក្ខវេ, ទេវានមិន្ទោ អវីតរាគោ អវីតទោសោ អវីត-
មោហោ ភីរុ ឆម្ភី ឧត្រាសី បលាយីតិ។

“អហញ្ច ខោ, ភិក្ខវេ, ឯវំ វទាមិ ‘សចេ តុម្ហាកំ, ភិក្ខវេ, អរញ្ញគតានំ វា រុក្ខមូលគតា-
នំ វា សុញ្ញាគារគតានំ វា ឧប្បជ្ជេយ្យ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, មមេវ តស្មឹ
សមយេ អនុស្សរេយ្យាថ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ
សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ។ មមញ្ហិ
វោ, ភិក្ខវេ, អនុស្សរតំ យំ ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, សោ បហីយិស្ស-
តិ។

“នោ ចេ មំ អនុស្សរេយ្យាថ, អថ ធម្មំ អនុស្សរេយ្យាថ ‘ស្វាក្ខាតោ ភគវតា ធម្មោ
សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនេយ្យិកោ បច្ចត្តំ វេទិតព្ពោ វិញ្ញូហី’តិ។ ធម្មញ្ហិ
វោ, ភិក្ខវេ, អនុស្សរតំ យំ ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, សោ បហីយិស្ស-
តិ។

“នោ ចេ ធម្មំ អនុស្សរេយ្យាថ, អថ សង្ឃំ អនុស្សរេយ្យាថ ‘សុប្បដិបន្នោ ភគវតោ
សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកស-
ង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ, យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិស-
បុគ្គលា ឯស ភគវតោ សាវកសង្ឃោ, អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជ-
លិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សា’តិ។ សង្ឃញ្ហិ វោ, ភិក្ខវេ, អនុស្សរតំ យំ
ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា, សោ បហីយិស្សតិ។

“តំ កិស្ស ហេតុ? តថាគតោ ហិ, ភិក្ខវេ, អរហំ សម្មាសម្ពុទ្ធោ វីតរាគោ វីតទោសោ វីតមោហោ អភីរុ អច្ឆម្ភី អនុត្រាសី អបលាយី”តិ។ ឥទមវោច ភគវា។ ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

“អរញ្ញេ រុក្ខមូលេ វា, សុញ្ញាគារេវ ភិក្ខវោ;
អនុស្សរេថ សម្ពុទ្ធំ, ភយំ តុម្ហាក នោ សិយា។
“នោ ចេ ពុទ្ធំ សរេយ្យាថ, លោកជេដ្ឋំ នរាសភំ;
អថ ធម្មំ សរេយ្យាថ, និយ្យានិកំ សុទេសិតំ។
“នោ ចេ ធម្មំ សរេយ្យាថ, និយ្យានិកំ សុទេសិតំ;
អថ សង្ឃំ សរេយ្យាថ, បុញ្ញក្ខេត្តំ អនុត្តរំ។
“ឯវំ ពុទ្ធំ សរន្តានំ, ធម្មំ សង្ឃញ្ច ភិក្ខវោ;
ភយំ វា ឆម្ភិតត្តំ វា, លោមហំសោ ន ហេស្សតី”តិ។

## ធជគ្គសូត្រ ទី៣ (បិដក)

[៣ ៤២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ។ ពួកភិក្ខុទាំងនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ។

[៣ ៤៣ ] ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកថា សង្គ្រាមទេវតា និងអសុរ បាន ផ្គុំគ្នា(ប្រទល់គ្នា) ហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ទេវរាជ ឈ្មោះសក្កៈជាធំជាងទេវតាទាំងឡាយ បាន ហៅពួកទេវតា ក្នុងឋានតាវត្តិង្សមកថា ម្នាលគ្នាយើង កាលបើពួកទេវតា ចូលកាន់សង្គ្រាមហើយ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម កើតឡើង ពួកអ្នកគប្បីក្រឡេកមើលចុងទង់ជ័យរបស់ខ្ញុំ ក្នុងសម័យនោះចុះ ។ ព្រោះថា កាលបើអ្នកទាំងឡាយ ក្រឡេកមើលចុងទង់ជ័យរបស់ខ្ញុំ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម ណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ មុខជានឹងស្ងប់រម្ងាប់ទៅវិញ ។ បើពួកអ្នកមិនក្រឡេកមើលចុងទង់ជ័យរបស់ខ្ញុំទេ ក៏ត្រូវតែក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះបជាបតិចុះ ។ ព្រោះថា កាលបើពួកអ្នកក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះ បជាបតិ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅវិញបាន ។ បើអ្នកទាំងឡាយ មិនក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះ បជាបតិទេ ក៏ត្រូវក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះ វរុណៈ ។ ព្រោះថា កាលបើពួកអ្នក ក្រឡេកមើលចុងទង់ជ័យ នៃទេវរាជ ឈ្មោះវរុណៈ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម ណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅវិញ ។ បើពួកអ្នកមិនក្រឡេកមើលចុងទង់ជ័យ នៃទេវរាជ ឈ្មោះវរុណៈទេ ត្រូវតែក្រឡេកមើលចុងទង់ជ័យ នៃទេវរាជឈ្មោះ ឦសាន ។ ព្រោះថា កាលបើពួកអ្នក ក្រឡេកមើលចុងទង់ជ័យ នៃទេវរាជ ឈ្មោះ ឦសាន សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម ណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ នឹងស្ងប់រម្ងាប់ទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកទេវតាក្រឡេកមើលចុងទង់ជ័យនោះ នៃទេវរាជ ឈ្មោះសក្កៈជាធំជាងទេវតាទាំងឡាយក្តី ក្រឡេកមើលចុងទង់ជ័យ នៃទេវរាជ ឈ្មោះបជាបតិក្តី ក្រឡេកមើលចុងទង់ជ័យ នៃទេវ

រាជ ឈ្មោះវរុណៈក្តី ក្រឡេកមើលចុងទង់ជ័យ នៃទេវរាជ ឈ្មោះឦសានៈក្តី សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម ណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ ក៏នឹងស្ងប់រម្ងាប់ ចួនកាល មិនស្ងប់រម្ងាប់ក៏មានខ្លះ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា សក្កទេវានមិន្ទ មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ជាអ្នកនៅខ្លាច នៅរន្ធត់ នៅតក់ស្លុត រត់ចេញនៅឡើយ ។

[៣៤៤] ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត ពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បើពួកអ្នកនៅក្នុងព្រៃ ឬនៅទៀបគល់ឈើ ឬនៅក្នុងផ្ទះស្ងាត់ សេចក្តីខ្លាចក្តី សេចក្តីរន្ធត់ក្តី ឬសេចក្តីព្រឺរោមក្តី កើតឡើង ពួកអ្នកគប្បីរឭករឿយៗ នូវតថាគត ក្នុងសម័យនោះថា ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ទ្រង់ជ្រាបច្បាស់នូវលោក ព្រះអង្គប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតា និងមនុស្ស ជាព្រះពុទ្ធ ទ្រង់ចែកនូវធម៌ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បើពួកអ្នករលឹករឿយៗ នូវតថាគត សេចក្តីខ្លាចក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី ណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ មុខជាស្ងប់រម្ងាប់ទៅ ។ បើពួកអ្នកមិនរឭករឿយៗ នូវតថាគតទេ គប្បីរឭករឿយៗ នូវព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ជាធម៌ដែលព្រះអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផល មិនរង់ចាំកាល ជាធម៌ដែលព្រះអរិយបុគ្គល គួរហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន ជាធម៌ដែលព្រះអរិយបុគ្គល គួរបង្អោនចូលមកទុកក្នុងចិត្តបាន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយ រឭករឿយៗ នូវធម៌ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម ណា នឹងកើតឡើង សេចក្តីខ្លាចជាដើមនោះ មុខជានឹងស្ងប់រម្ងាប់ទៅបាន ។ បើអ្នកទាំងឡាយ មិនរឭកនូវធម៌ទេ គប្បីរឭកនូវសង្ឃថា ព្រះសង្ឃសាវ័កនៃព្រះ

មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយដោយត្រង់ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយ ដើម្បីព្រះនិព្វាន ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ លោកប្រតិបត្តិហើយ ដោយត្រឹមត្រូវ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគ រាប់ជាគូនៃបុរស មាន៤គូ រាប់រៀងជាបុរសបុគ្គល មាន៨ ព្រះសង្ឃសាវ័កនៃព្រះមានព្រះភាគនុ៎ះ លោកគួរទទួលនូវគ្រឿងបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តប្រសើរបំផុត របស់សត្វលោក។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បើអ្នកទាំងឡាយ រឭកនូវសង្ឃ សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម ណា នឹងកើតឡើង សេចក្តីខ្លាច ជាដើមនោះ មុខជានឹងស្ងប់រម្ងាប់ទៅបាន សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា តថាគត ជាអរហន្ត សម្មាសម្ពុទ្ធ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនខ្លាច មិនរន្ធត់ មិនតក់ស្លុត មិនរត់ចេញទេ។

[៣៤៥] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគត ត្រាស់នូវព្រះពុទ្ធដីកានេះហើយ លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់ព្រះពុទ្ធដីកានេះ តទៅទៀតថា ម្នាលភិក្ខុទាំងឡាយ កាលបើអ្នករាល់គ្នានៅក្នុងព្រៃ ឬទៀបគល់ឈើ ឬក្នុងផ្ទះស្ងាត់ គប្បីរឭករឿយៗ នូវព្រះសម្ពុទ្ធ ភ័យនឹងមិនមានដល់ពួកអ្នកទេ បើអ្នកទាំងឡាយ មិនបានរលឹកនូវព្រះពុទ្ធ ដែលជាធំបំផុតក្នុងលោក ជានរៈអង់អាចទេ គប្បីរឭកធម៌ ជាធម៌ស្រោចស្រង់សត្វ ដែលតថាគតសំដែងល្អហើយ បើអ្នកទាំងឡាយ មិនបានរឭកធម៌ ជាធម៌ស្រោចស្រង់សត្វ ដែលតថាគត សំដែងល្អហើយទេ គប្បីរឭកសង្ឃ ជាបុញ្ញក្ខេត្តប្រសើរបំផុត (របស់សត្វលោកចុះ)។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នករាល់គ្នារឭកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃយ៉ាងនេះ ភ័យក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី នឹងមិនមានឡើយ។

### ៣. ធជគ្គសុត្តវណ្ណនា (អដ្ឋកថា)

២៤៩. តតិយេ សមុបព្យូឡ្ហោតិ សម្បិណ្ឌិតោ រាសិភូតោ។ ធជគ្គំ ឧល្លោកេយ្យថាតិ សក្កស្ស កិរ ទិយឌ្ឍយោជនសតាយាមោ រថោ។ តស្ស ហិ បច្ឆិមន្តោ បណ្ណាសយោជនោ, មជ្ឈេ រថបញ្ជរោ បណ្ណាសយោជនោ, រថសន្ធិតោ យាវ រថសីសា បណ្ណាសយោជនានិ។ តទេវ បមាណំ ទិគុណំ កត្វា តិយោជនសតាយាមោតិបិ វទន្តិយេវ។ តស្មឹ យោជនិកបល្ល-ង្កោ អត្ថតោ, តិយោជនិកំ សេតច្ឆត្តំ មត្ថកេ ឋបិតំ, ឯកស្មឹយេវ យុគេ សហស្សអាជញ្ញា យុត្តា, សេសាលង្ការស្ស បមាណំ នត្ថិ។ ធជោ បនស្ស អឌ្ឍតិយានិ យោជនសតានិ ឧគ្គតោ, យស្ស វាតាហតស្ស បញ្ចង្គិកតូរិយស្សេវ សទ្ទោ និច្ឆរតិ, តំ ឧល្លោកេយ្យាថាតិ វទតិ។ កស្មា? តំ បស្សន្តានញ្ហិ រាជា នោ អាគន្ត្វា បរិសបរិយន្តេ និខាតថម្ភោ វិយ ឋិតោ, កស្ស មយំ ភាយាមាតិ ភយំ ន ហោតិ។ បជាបតិស្សាតិ សោ កិរ សក្កេន សមានវណ្ណោ សមានាយុកោ ទុតិយំ អាសនំ លភតិ។ តថា វរុណោ ឦសានោ ច។ វរុណោ បន តតិយំ អាសនំ លភតិ, ឦសានោ ចតុត្ថំ។ បលាយីតិ អសុរេហិ បរាជិតោ តស្មឹ រថេ ឋិតោ អប្បម-ត្តកម្បិ វេធំ ទិស្វា បលាយនធម្មោ។

ឥតិបិ សោ ភគវាតិអាទីនិ វិសុទ្ធិមគ្គេ វិត្ថារិតានេវ។ ឥទមវោចាតិ ឥទំ ធជគ្គបរិត្តំ នាម ភគវា អវោច, យស្ស អាណាខេត្តេ កោដិសតសហស្សចក្កវាឡេ អានុភាវោ វត្តតិ។ ឥទំ អាវជ្ជេត្វា ហិ យក្ខភយចោរភយាទីហិ ទុក្ខេហិ មុត្តានំ អន្តោ នត្ថិ។ តិដ្ឋតុ អញ្ញ ទុក្ខូប-សមោ, ឥទំ អាវជ្ជមានោ ហិ បសន្នចិត្តោ អាកាសេបិ បតិដ្ឋំ លភតិ។

តត្រិទំ វត្ថុ ទីឃវាបិចេតិយម្ហិ កិរ សុធាកម្មេ កយិរមានេ ឯកោ ទហរោ មុទ្ធវេទិកាបាទតោ បតិត្វា ចេតិយកុច្ឆិយា ភស្សតិ។ ហេដ្ឋា ឋិតោ ភិក្ខុសង្ឃោ “ធជគ្គបរិត្តំ, អាវុសោ,

អាវដ្ឋាហី"តិ អាហ។ សោ មរណភយេន តដ្ឋិតោ "ធជគ្គបរិត្តំ មំ រក្ខតូ"តិ អាហ។ តាវទេវ-ស្ស ចេតិយកុច្ឆិតោ ទ្វេ ឥដ្ឋកា និក្ខមិត្វា សោបានំ ហុត្វា អដ្ឋំសុ, ឧបរិដ្ឋិតោ វល្លិនិស្សេណឹ ឱតារេសុំ។ តស្មិំ និស្សេណិយំ ឋិតេ ឥដ្ឋកា យថាដ្ឋានេយេវ អដ្ឋំសុ។ តតិយំ។

# អ ដ្ឋ ក ថា

## ធជគ្គសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យ **ក្នុងធជគ្គសូត្រទី ៣** តទៅនេះ ៖

[៣៤៣] បទថា **សមុបព្យូឡ្ហា** គឺ ប្រជុំគ្នា រួមគ្នាជាកង ។ បទថា **ធជគ្គំ ឧស្សាបេយ្យាថ** សេចក្តីថា បានឮថា រថរបស់ស្តេចសក្កៈប្រវែង ១៥០ យោជន៍ ផ្នែកខាងក្រោយនៃរថនោះប្រវែង ៥០ យោជន៍ កណ្តាលតួរថប្រវែង ៥០ យោជន៍ ផ្នែកក្បាលនៃរថប្រវែង ៥០ យោជន៍ ។ អាចារ្យពួកខ្លះពង្រីកប្រមាណនោះជា ២ ស្មើគ្នា ពោលថា ប្រវែង ៣០០ យោជន៍ខ្លះ ។ ក្នុងរថនោះ តាំងទុកនូវបល្ល័ង្កប្រមាណមួយយោជន៍ តាំងឆត្រសកម្ពស់ ៣ យោជន៍ ទុកខាងលើ ។ ត្រង់ទឹមមួយ ទឹមសេះអាជានេយ្យ ១.០០០ ។ គ្រឿងតាក់តែងដ៏សេសមិនមានប្រមាណ (គឺរាប់មិនបាន) ។ ក៏ទង់របស់រថនោះ លើកឡើងកម្ពស់ ២៥០ យោជន៍ ។ ទង់ដែលត្រូវខ្យល់បក់ ក៏មានសំឡេងដូចជាតន្ត្រីប្រកបដោយអង្គ ៥ សក្កទេវរាជត្រាស់ថា ពួកអ្នកចូរមើលទង់នោះ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះកាលពួកទេវតាឃើញទង់នោះ គិតថា

ព្រះរាជារបស់យើងមកឈរនៅក្នុងទីខាងចុងបរិស័ទ ដូចសសរដែលគេកប់ យើងមិនខ្លាចអ្នកណា ដូច្នេះ ទើបមិនខ្លាច ។

បទថា **បជាបតិស្ស** សេចក្តីថា បានឮថា បជាបតិទេវរាជនោះ មានពណ៌សម្បុរដូចទីងសក្កទេវរាជ មានអាយុស្មើគ្នា បានទីអង្គុយក្នុងលំដាប់ទី ២ ។ បន្ទាប់មកក៏វរុណទេវរាជ និងឦសានទេវរាជ ។ ឯវរុណទេវរាជបានទីអង្គុយក្នុងលំដាប់ ទី ៣ ឦសានទេវរាជបានទីអង្គុយក្នុងលំដាប់ទី ៤ ។ បទថា **បលាយិ** សេចក្តីថា ចាញ់ពួកអសុរហើយឈរត្រង់រថនោះ ឬឃើញទង់សូម្បីមានប្រមាណតិច ក៏គេចចេញទៅជាធម្មតា ។

[៣៨៤] បទថា ***ឥតិបិ សោ ភគវា*** ជាដើម មានសេចក្តីពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

[៣៨៥] បទថា ***ឥទមវោច*** សេចក្តីថា ព្រះមានព្រះភាគបានត្រាស់ធជគ្គបរិត្តនេះ ។ អានុភាពរបស់បរិត្តណា រមែងប្រព្រឹត្តទៅក្នុងអាណាខេត្ត គឺ ក្នុងសែនកោដិចក្រវាឡ ។

ពិតហើយ បុគ្គលទាំងឡាយនឹកដល់បរិត្តនេះ រមែងផុតចាកទុក្ខ មានយក្ខភ័យ និងចោរភ័យជាដើម មានចំនួនរាប់មិនបាន ។ សេចក្តីស្ងប់អំពីទុក្ខ

ដទៃចូរលើកទុកចុះ ។ ពិតណាស់ អ្នកមានចិត្តជ្រះថ្លាហើយ ទឹកដល់បរិត្ត នេះ រមែងបានទីពឹងសូម្បីក្នុងអាកាស ។ ក្នុងសេចក្ដីនោះ មានរឿងដូច្នេះ ។

បានឮថា កាលគេកំពុងលាបកំបោរសេត្រង់ទីយវាបំចេតិយ ប្រុសកម្លោះម្នាក់ភ្លាត់ជើងធ្លាក់ពីវេទីកាជាន់លើ ចុះមកត្រង់ប្រហោងព្រះចេតិយ ។ ភិក្ខុសង្ឃឈរខាងក្រោម ពោលថា អ្នកចូរទឹកដល់ធជគ្គបរិត្ត ។ គេតក់ស្លុតភ័យខ្លាចស្លាប់ ទើបពោលថា ធជគ្គបរិត្តជួយខ្ញុំផង ដូច្នេះ ។ ឥដ្ឋ ២ ដុំ ក៏ផុសចេញមកអំពីប្រហោងចេតិយ តាំងជាជណ្ដើរឲ្យគេភ្លាម ។ មនុស្សទាំងឡាយក៏ទម្លាក់ជណ្ដើរវល្លិ៍ដែលនៅខាងលើ ។ ឥដ្ឋដែលធ្វើជាជណ្ដើរនោះ ក៏តាំងនៅដូចដើម ។

**ចប់អដ្ឋកថា ធជគ្គសូត្រ ទី៣**

## ៣ .ធជគ្គសុត្តវណ្ណនា (ដីកា)

២៤៩.សមុបព្យូឡ្ហោតិ ឧភិន្នំ សហ ឯវ សមាគមោ, កុសំ វា ព្យូឡ្ហោតិ អត្ថោ កុសាបនស្ស ព្យូឡ្ហតា ទ្វិន្នំ សេនានំ សមាគន្ត្វា សម្បិណ្ឌិតការេនាតិ អាហ "សម្បិណ្ឌិតោ រាសិភូតោ"តិ។ បច្ឆិមន្តោតិ រថបញ្ជរស្ស បរន្តោ បច្ឆិមន្តោ បច្ឆិមកោដ្ឋាសោ។ រថសន្ធិតោតិ រថបញ្ជរស្ស កុព្វរេន សទ្ធឹ សម្ពន្ធនដ្ឋានតោ។ តទេវ បមាណន្តិ តទេវ "ទិយឌ្ឍយោជនសតាយាមោ"តិ វុត្តប្បមាណមេវ។ ទិគុណំ កត្វាតិ "បច្ឆិមន្តោ សតយោជនោ"តិអាទិនា ទិគុណំ កត្វា។ ចន្ទមណ្ឌលសូរិយមណ្ឌលកិង្កិណិកជាលាទិភេទស្ស សេសាលង្ការស្ស។ បស្សន្តានំ ទេវានំ។ រាជា នោតិ អម្ហាកំ រាជា ទេវសេដ្ឋោ។ ទុតិយំ អាសនំ លភតីតិ សក្កេ និសិន្នេ តស្ស អនន្តរំ ទុតិយំ អាសនំ លភតិ។ តស្មា ទេវសេដ្ឋតាយ សក្កោ វិយ គារវដ្ឋានិយោ, យតោ សក្កោ "តស្ស ធជគ្គំ ឧល្លោកេយ្យាថា"តិ អាហ។ ឯស នយោ សេសេសុបិ។ អសុរេហិ បរាជិតោតិ អសុរេហិ បរាជយំ អាបាទិតោ។ រជធជំ ទិស្វាតិ បរសេនាយ ឧបគច្ឆន្តិយា ឧដ្ឋិតរជមត្តម្បិ ទិស្វា ឋិតោបិ តំ រជធជំ ទិស្វា ភីរុការេន បលាយនធម្មោ។

យស្ស ធជគ្គបរិត្តស្ស អានុភាវោ វត្តតិ អសម្មុខីភូតាហិបិ ទេវតាហិ សិរសា សម្បដិច្ឆិតព្វតោ។ ចោរភយាទីហីតិ អាទិសទ្ទេន រោគភយាទីនញ្ចេវ វដ្ដទុក្ខស្ស ច សង្គហោ ទដ្ឋព្វោ វិធិនា ភាវិតេ បរិត្តស្ស អត្ថេ ឧបចារជ្ឈានាទីនម្បិ ឥជ្ឈនតោ។

ទីឃវាបីនាមកេ គាមេ ចេតិយំ ទីឃវាបិចេតិយំ។ មុទ្ធវេទិកា នាម ហម្មិយំ បរិក្ខិបិត្វា កតវេទិកា។ ពុទ្ធគតំ សតឹ ឧបដ្ឋបេត្វា បរិត្តរក្ខគុត្តឹ អាហ។ បរិត្តស្ស អានុភាវេន ទ្វេ ឥដ្ឋកា...បេ... អដ្ឋំសុ។ តថា ហិ តស្មឹ និស្សេណិយំ ឋិតេ...បេ... អដ្ឋំសូតិ។

ធជគ្គសុត្តវណ្ណនា និដ្ឋិតា។

## ការពណ៌នាធជគ្គសូត្រ (ដីកា)

ពាក្យថា សង្គ្រាមពួកអសុរ និងទេវតា បានមកប្រជល់គ្នាហើយ មានសេចក្តីថា ការមកប្រជុំគ្នានោះឯង ព្រមគ្នាទាំងពីរខាង ឬក៏ការតទល់ បានប្រជុំគ្នាហើយ ។ម្យ៉ាងវិញទៀត ការតទល់ បានប្រជុំគ្នាហើយនៃពួកអសុរ និងពួកទេវតានោះ ហើយបានមកប្រជុំគ្នានៃពួកសេនាទាំងពីរខាង ហើយពោលដោយសម្បិណ្ឌិត (ការរួមពួកបណ្ឌិត) សព្ទថា ការរួមគ្នាជាមួយពួកបណ្ឌិតកើតឡើងហើយ ។ពាក្យថា បច្ឆិមន្តោ (ក្នុងខាងក្រោយ) មានសេចក្តីថា ចំណែកខាងក្រោយ ក្នុងខាងក្រោយដទៃនៃក្បួនរថបញ្ជរ។ពាក្យថា រថ-សន្ធិតោ (អំពីតំណរនៃរថ) មានសេចក្តីថា អំពីទីតាំងជាប់គ្នាជាមួយនឹងការធ្វើក្បួនរថបញ្ជរ។ត្រឹមប្រមាណនោះឯង មានសេចក្តីថា ត្រឹមប្រមាណដែលលោកពោលហើយថា មួយយោជន៍កន្លះ និង ១០០ ព្យាម ។ពាក្យថា ទិគុណំ កត្វា (ធ្វើជាទ្វេគុណ) មានសេចក្តីថា ធ្វើហើយជាទ្វេគុណជាដើមថា ១០០ យោជន៍ ក្នុងកាលជាខាងក្រោយ នៃការប្រដាប់តាក់តែងដ៏សេស មានការផ្សេងគ្នាដោយពន្លឺមានមណ្ឌលព្រះចន្ទ និងមណ្ឌលព្រះអាទិត្យ កាលឃើញនៃទេវតាទាំងឡាយ ។ពាក្យថា រាជា នោ (ជាស្តេចនៃយើងទាំងឡាយ) មានសេចក្តីថា ជាស្តេចប្រសើរជាទេវតានៃយើងទាំងឡាយ ។ពាក្យថា ទុតិយំ អាសនំ លភតិ (រមែងបាននូវអាសនៈទីពីរ) មានសេចក្តីថា កាលដែលសក្កៈគង់នៅរមែងបាននូវអាសនៈទីពីរក្នុងចន្លោះនៃទេវតានោះ ។ព្រោះហេតុនោះ ការគោរពដូចជាសក្កៈដ៏ប្រសើរជាងទេវតាទាំងឡាយ ទើបលោកពោលថា គប្បីក្រឡេកមើលចុងទង់ជ័យនៃស្តេចសក្កៈក្នុងកាលនោះ កុំខានឡើយ។សូម្បីន័យដ៏សេស គប្បីជ្រាបតាមន័យនោះឯង។ពាក្យថា អសុរេហិ បរាជិតោ (បរាជ័យហើយនៃពួកអសុរទាំងឡាយ) មានសេចក្តីថា ដល់ការបរាជ័យនៃពួកអសុរទាំងឡាយ ។ពាក្យថា វេជជំ ទិស្វា (ឃើញ

ហើយនូវទង់ដែលជ្រលក់ដោយពណ៌) មានសេចក្តីថា កាលពួកសេនាដទៃ ចូលទៅ ហើយឃើញសូម្បីត្រឹមតែទង់ជ្រលក់ពណ៌ដែលតាំងឡើង ហើយឃើញនូវទង់ជ្រលក់ពណ៌ដែលឋិតនៅ ធម៌ដែលនាំឲ្យរត់ ព្រោះភ័យខ្លាច (រមែងមិនមាន) ។

អានុភាពនៃធជគ្គបរិត្តឯណា រមែងប្រព្រឹត្តទៅ គប្បីសម្រេចអំពីទេវតាទាំងឡាយនមស្ការដោយសិរសាសូម្បីក្នុងទីមិនចំពោះមុខ ។ បទថា ចោរភយាទីហិ (ដោយភ័យអំពីចោរជាដើម) មានសេចក្តីថា ការសង្គ្រោះគប្បីជ្រាបថា ភ័យអំពីរោគជាដើមផង និងភ័យអំពីសេចក្តីទុក្ខក្នុងវដ្ដៈផង ដោយអាទិសព្ទគឺគៅបង់ចែកផ្សេងគ្នាសម្រេចហើយសូម្បីឧបចារជ្ឈានជាដើមក្នុងអត្ថ ។

ចេតិយក្នុងស្រុកឈ្មោះថា ទីឃវាបិនាមក ជាឈ្មោះ ទីឃវាបិចេតិយ ។ ឈ្មោះថា គំនរដីដែលគេគរឲ្យខ្ពស់ដូចជាចេតិយអំពីក្បាលទៅ ឈ្មោះថា កតវេទិកា (គំនរដីដែលគេគរឲ្យខ្ពស់ដូចជាចេតិយធ្វើហើយ) ។ លើកឡើងនូវសតិឲ្យដូចជាដំណើរព្រះពុទ្ធ ហើយធ្វើការគ្រប់គ្រងរក្សានូវព្រះបរិត្ត ។ អ្នកសម្រេចផលពីរយ៉ាងឋិតនៅហើយដោយអានុភាពនៃព្រះបរិត្ត ។ល។ ពិតដូច្នោះមែន គឺគេឋិតនៅក្នុងការតាំងចិត្តនោះ ។ល។ តាំងនៅហើយ ។

ចប់ការពណ៌នាធជគ្គសូត្រ